multicultural communication

NSW HEALTH

Khmer
September 2005
[DOH-6970]

# ជំងឺគ្រុនផ្តាសាយបក្សី

# Avian Influenza (“Bird Flu”)

**ចេញនៅថ្ងៃ: 29 ខែកញ្ញា ឆ្នាំ 2005**

បណ្តាអ្នកជំនាញការខាងជំងឺគ្រុនផ្តាសាយមានការបារម្ភថា ការឃាយីនាពេលថ្មីៗនៃអំបូរវីរុសប្រភេទ H5N1 ក្នុងចំណោមបក្សី អាចធ្វើឲ្យវីរុសនេះប្រែខ្លួនទៅជាអំបូរថ្មីមួយនៃវីរុសគ្រុនផ្តាសាយ។ ការឆ្លងរាតត្បាតខ្លាំងដោយកន្លែងនៃជំងឺគ្រុនផ្តាសាយនេះ អាចកើតមានឡើងពាសពេញពិភពលោក ។ មកទល់ពេលនេះ ពុំមានការបញ្ជាក់ ឬក៏ករណីដែលគេសង្ស័យថាជាជំងឺផ្តាសាយបក្សី នៅក្នុងប្រទេសអូស្ត្រាលីឡើយ។

**តើជំងឺគ្រុនផ្តាសាយបក្សីជាអ្វី?**

គ្រុនផ្តាសាយបក្សីជាជំងឺឆ្លងឃាយីពពួកបក្សី។ តាមធម្មតា វីរុសឆ្លងនៅក្នុងចំណោមពពួកសត្វបក្សីព្រៃដោយមិនបង្កឲ្យមានជំងឺឡើយ ឬក៏ធ្វើឲ្យមានជំងឺស្រាលតែប៉ុណ្ណោះ។ ការឆ្លងរោគនៅក្នុងចំណោមពពួកសត្វបក្សីស្រុក មានដូចជាមាន់ជាដើម អាចបង្កឲ្យមានជំងឺធ្ងន់ធ្ងរនៅក្នុងចំណោមសត្វស្លាបទាំងនោះ។ ជំងឺគ្រុនផ្តាសាយបក្សីមានប្រភេទខុសៗគ្នា ហើយមានតែ ២-៣ប្រភេទទេដែលអាចធ្វើឲ្យមានជំងឺនៅក្នុងចំណោមមនុស្សលោក។

ប្រភេទថ្មីមួយនៃជំងឺគ្រុនផ្តាសាយបក្សីហៅថា គ្រុនផ្តាសាយ A H5N1 ត្រូវបានគេទទួលស្គាល់ជាលើកដំបូងនៅឆ្នាំ 1997 នៅហុងកុង។ ប្រភេទវីរុសនេះបានលេចរូបរាងម្តងទៀតនៅចុងឆ្នាំ ២០០៣ ហើយបានឆ្លងរាលដាលយ៉ាងលឿនទៅប្រទេសអាស៊ីជាច្រើន បង្កឲ្យមានការឆ្លងរោគយ៉ាងខ្លាំងនៅក្នុងចំណោមហ្វូងមាន់ទាក្នុងស្រុកជាច្រើន។ បច្ចុប្បន្ននេះ គេមិនមានភស្តុតាង ដែលបង្ហាញថា ជំងឺគ្រុនផ្តាសាយបក្សីកំពុងតែឃាយីបក្សីនៅក្នុងប្រទេសអូស្ត្រាលីនោះទេ។

វីរុសនេះក៏បានឆ្លងឃាយីមនុស្សមួយចំនួនដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងមាន់ទាដែលឈឺ ឬក៏ជាមួយលាមកមាន់ទា។ ចាប់តាំងពីថ្ងៃទី 28 ខែធ្នូ ឆ្នាំ 2003 មក គេបានរាយការណ៍អំពីការឆ្លងរោគចំនួនជាង 110 ករណី ដោយមានការបញ្ជាក់ថាជាជំងឺគ្រុនផ្តាសាយបក្សីដែលឆ្លងឃាយីមនុស្សលោក នៅប្រទេសថៃ វៀតណាម កម្ពុជា និង ឥណ្ឌូនេស៊ី ហើយភាគច្រើននៃជនដែលឆ្លងជំងឺនេះបានបាត់បង់ជីវិតហើយ។

នៅក្នុងដំណាក់កាលនេះ មនុស្សដែលឆ្លងវីរុស H5N1 មិនទំនងជាមានលទ្ធភាពចម្លងវីរុសនេះទៅមនុស្សឯទៀតដោយងាយស្រួលឡើយ។ ការប៉ះពាល់សត្វមាន់ទាមានជំងឺ ឬក៏លាមកសត្វទាំងនោះ (ឬក៏ធូលី ឬក៏ដីដែលមានផ្ទុកលាមកសត្វមាន់ទា) អាចបណ្តាលឲ្យមានការឆ្លងជំងឺនេះទៅមនុស្សលោកបាន។ ការទទួលទានផលិតផលមាន់ទាដែលចំអិនរួច ដោយរួមទាំងសាច់មាន់ ឬស៊ុតនោះ មិនបណ្តាលឲ្យមានការឆ្លងជំងឺឡើយ។

គេហៅការឆ្លងរាតត្បាតខ្លាំងដោយកន្លែង នៅពាសពេញពិភពលោកថា ជាការឆ្លងរាតត្បាតទូទៅ។ ការឆ្លងរាតត្បាតទូទៅកើតមានឡើងនៅពេលដែលវីរុសថ្មីឃាយីមនុស្សដែលគ្មានអង្គធាតុការពារខ្លួន ឬក៏មានអង្គធាតុការពារខ្លួនតិចតួច។ ការឆ្លងរាតត្បាតទូទៅនៃជំងឺគ្រុនផ្តាសាយនៅគ្រាមុនៗ បានកើតឡើងនៅឆ្នាំ 1918-19, 1957-58 និង 1968-69 ។ នៅក្នុងការឆ្លងរាតត្បាតទូទៅពី ឆ្នាំ 1918-19 មានមនុស្សរវាងពី 20 ទៅ 40 លាននាក់បានស្លាប់។ អ្នកវិទ្យាសាស្ត្រជាច្រើនមានការបារម្ភថា ការឃាយីនៃវីរុស H5N1 នាពេលថ្មីៗនៅក្នុងចំណោមពពួកបក្សីអាចនាំឲ្យវីរុសនេះបំរែបំរួលខ្លួនទៅជាប្រភេទថ្មីមួយនៃវីរុសជំងឺគ្រុនផ្តាសាយ ដែលឆ្លងដោយងាយស្រួលក្នុងចំណោមមនុស្សទាំងពួង បណ្តាលឲ្យមានការឆ្លងរាតត្បាតទូទៅមួយ។

## តើរោគសញ្ញានៃជំងឺគ្រុនផ្តាសាយបក្សីមានអ្វីខ្លះ?

ប្រភេទផ្សេងៗគ្នានៃជំងឺគ្រុនផ្តាសាយបក្សីអាចធ្វើឲ្យមានរោគសញ្ញាផ្សេងៗគ្នា នៅក្នុងចំណោមនុស្សលោក។ ប្រភេទវីរុស ទាំងអស់អាចបង្កឲ្យមានរោគសញ្ញាស្រដៀងគ្នាទៅនឹងជំងឺគ្រុនផ្តាសាយមនុស្ស (ឡើងកំដៅ, ក្អក, អស់កម្លាំង, ឈឺសាច់ដុំ, ឈឺបំពង់ក, ដកដង្ហើមផុតៗ, ហៀរសំបោរ, ឈឺក្បាល)។ នៅក្នុងករណីខ្លះ វីរុស H5N1 បានធ្វើឲ្យមានការរលាកហើមសួតយ៉ាងធ្ងន់ធ្ងរ ហើយនៅក្នុងចំណោមករណីមួយចំនួនទៀតនោះ អ្នកជំងឺបានមានបញ្ហារលាកស្រោមខួរ ឬក៏រាករូស។ រោគសញ្ញាទូទៅបំផុតចំពោះមនុស្សដែលឆ្លងវីរុស H7 គឺភ្នែកឡើងក្រហម (ការរលាកភ្នាសភ្នែក)។ ការចេញរោគសញ្ញា ជាទូទៅកើតមានឡើងរវាងពី 2 ទៅ 4 ថ្ងៃ ក្រោយពីមានការប៉ះពាល់មេរោគរួច។

## តើនរណាខ្លះដែលប្រឈមមុខនឹងលទ្ធភាពនៃការឆ្លងរោគ?

មនុស្សភាគច្រើនមិនប្រឈមមុខនឹងលទ្ធភាពនៃការឆ្លងរោគនេះឡើយ។ មនុស្សដែលប្រឈមមុខនឹងលទ្ធភាពនៃការឆ្លងវីរុស H5N1 គឺជាអ្នកដែលមានការប៉ះពាល់ជាមួយនឹងបក្សីឈឺ ឬក៏លាមកបក្សីទាំងនោះ នៅគ្រាដែលគេរស់នៅ ឬក៏ធ្វើដំណើរឆ្លងកាត់តំបន់ដែលមានវីរុសនេះ ឬ (ជារឿងដែលកម្រ) អ្នកដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងជនណាមួយដែលមានប្រភេទជំងឺគ្រុនផ្តាសាយបក្សីឆ្លងមកមនុស្ស នៅក្នុងតំបន់ដែលឆ្លងរោគ។

## តើគេការពារវារាំងជំងឺនេះដោយរបៀបណា?

គេមិនទាន់មានវ៉ាក់សាំងបង្ការរោគសំរាប់មនុស្សលោកដើម្បីទប់ទល់នឹងប្រភេទថ្មីនៃជំងឺគ្រុនផ្តាសាយបក្សីឡើយ។ វ៉ាក់សាំងធម្មតាដែលមានសព្វថ្ងៃនេះ សំរាប់ជំងឺគ្រុនផ្តាសាយមនុស្ស នឹងមិនមានសមត្ថភាពទប់ទល់រារាំងជំងឺគ្រុនផ្តាសាយបក្សីឡើយ ដោយរួមទាំងប្រភេទវីរុស H5N1 ផង។ បច្ចុប្បន្ននេះ បណ្តាអ្នកវិទ្យាសាស្ត្រនៅពាសពេញពិភពលោក កំពុងតែប្រឹងប្រែងបង្កើតវ៉ាក់សាំងសមរម្យមួយសំរាប់ប្រភេទវីរុសនេះ។

## តើគេធ្វើរោគវិនិច្ឆ័យដោយរបៀបណា?

គេអាចធ្វើរោគវិនិច្ឆ័យជំងឺគ្រុនផ្តាសាយបក្សី ដោយការយកសំណាកឈាម សំបោរ ឬក៏រំអិលដែលកៀរចេញពីច្រមុះនិងបំពង់ក។ ការធ្វើតេស្តគឺធ្វើឡើង នៅឯមន្ទីរពិសោធន៍ពិសេសមួយ។

## តើគេព្យាបាលជំងឺនេះដោយរបៀបណា?

ថ្នាំប្រឆាំងគ្រុនផ្តាសាយជាក់លាក់មួយចំនួន ទំនងជាមានប្រសិទ្ធភាពទប់ទល់នឹងជំងឺគ្រុនផ្តាសាយបក្សីដែលឃាយីមនុស្ស ហើយគេប្រើថ្នាំទាំងនេះ ដើម្បីព្យាបាលមនុស្សដែលមានវីរុស H5N1 ។

## តើការឆ្លើយតបផ្នែកសុខាភិបាលសាធារណៈវិញ មានលក្ខណៈយ៉ាងណាដែរ?

ប្រភេទផ្សេងៗគ្នានៃជំងឺគ្រុនផ្តាសាយបក្សីបានកើតមានឡើងនៅក្នុងប្រទេសអូស្ត្រាលីនៅគ្រាកន្លងមក។ យ៉ាងណាមិញ គេមិនទាន់មានរបាយការណ៍នាគ្រាថ្មីៗ ស្តីអំពីជំងឺគ្រុនផ្តាសាយបក្សីនៅក្នុងចំណោមបក្សីអូស្ត្រាលីនៅឡើយទេ ហើយក៏គ្មានរបាយការណ៍អំពីពលរដ្ឋអូស្ត្រាលី ដែលឆ្លងវីរុស H5N1 ដែរ។ ប្រទេសអូស្ត្រាលីមិននាំចូលមាន់ទារស់ ឬក៏ផលិតផលមាន់ទាឆៅពីអាស៊ីឡើយ ហើយអូស្ត្រាលីមានប្រព័ន្ធឃ្លាំពិនិត្យមើលការនាំចូលដោយខុសច្បាប់នៃបក្សី ឬក៏ផលិតផលបក្សីនៅតាមព្រំប្រទល់អូស្ត្រាលី ។

បើសិនជាមានករណីដែលគេសង្ស័យថាជាករណីឆ្លងជំងឺគ្រុនផ្តាសាយបក្សីមកមនុស្ស នៅក្នុងរដ្ឋ NSW នោះ ក្រសួងសុខាភិបាលរដ្ឋ NSW នឹងធ្វើការជាមួយអ្នកជំងឺ វេជ្ជបណ្ឌិតព្យាបាលរោគ និងមន្ទីរពិសោធន៍ ដើម្បីបញ្ជាក់អំពីការវិនិច្ឆ័យរោគ។ ករណីដែលគេសង្ស័យទាំងប៉ុន្មាន នឹងត្រូវគេដាក់ឲ្យនៅដាច់ពីគេឯង ដើម្បីរាំងកុំឲ្យមានការចម្លងថែមទៀតទៅអ្នកដទៃ។ សាច់ញាតិជិតស្និទ្ធជាមួយនឹងអ្នកជំងឺទាំងនោះ ដែលប្រហែលជាមានការប៉ះពាល់នឹងវីរុស នឹងទទួលព័ត៌មានអំពីលទ្ធភាពនៃការឆ្លងរោគ។  បើសិនជាអ្នកទាំងនោះមានរោគសញ្ញាផងដែរនោះ គេនឹងដាក់ជនទាំងនោះឲ្យនៅដាច់ពីគេឯងផងដែរ ហើយគេនឹងធ្វើតេស្តរកមើលជំងឺគ្រុនផ្តាសាយបក្សី។

## ឱវាទសំរាប់ការធ្វើដំណើរ

ពលរដ្ឋអូស្ត្រាលីដែលធ្វើដំណើរទៅកាន់កន្លែងមានជំងឺគ្រុនផ្តាសាយបក្សីអាចបន្ថយលទ្ធភាពនៃគ្រោះថ្នាក់ឆ្លងរោគបាន ដោយការចៀសវាងកុំទៅកសិដ្ឋានចិញ្ចឹមមាន់ទា និងផ្សារដែលមានលក់បក្សីរស់។ អ្នកធ្វើដំណើរទាំងនោះ គប្បីធ្វើយ៉ាងណាឲ្យមានការប្រកាន់ខ្ជាប់នូវអនាម័យ នៅពេលមានការកាន់ប៉ះពាល់សាច់មាន់ទាឬស៊ុតឆៅ ហើយត្រូវមានការលាងដៃឲ្យបានស្អាតត្រឹមត្រូវ ក្រោយពីមានការប៉ះពាល់គ្រឿងទាំងនោះ ព្រមទាំងធ្វើយ៉ាងណាឲ្យមានការចំអិនសាច់មាន់ទាឲ្យបានឆ្អិនល្អ មុននឹងបរិភោគអាហារទាំងនោះ។

## ចំពោះព័ត៌មានបន្ថែម

លេខទូរស័ព្ទគ្រាអាសន្ននៃក្រសួងសុខាភិបាលនិងជនវ័យជរានៃរដ្ឋាភិបាលអូស្ត្រាលី
(Australian Government Department of Health and Ageing information hotline)
**1800 004 599.**

## ការភ្ជាប់ទៅវិបសាយពាក់ព័ន្ធទាំងឡាយ (**Related links**)

ប័ណ្ណព័ត៌មានគ្រុនផ្តាសាយនៃក្រសួងសុខាភិបាលរដ្ឋ NSW (ជាទូទៅគ្រុនផ្តាសាយមនុស្ស)
NSW Health influenza factsheet (usual human influenza)
http://www.health.nsw.gov.au/pubs/topics/Influenza.pdf

លេខទូរស័ព្ទគ្រាអាសន្ននៃក្រសួងសុខាភិបាលនិងជនវ័យជរានៃរដ្ឋាភិបាលអូស្ត្រាលី – ជំងឺគ្រុនផ្តាសាយបក្សី
Australian Government Department of Health and Ageing – Avian influenza
http://www.health.gov.au/internet/wcms/publishing.nsf/Content/health-avian_influenza-index.htm

អង្គការសុខភាពពិភពលោក
World Health Organization
http://www.who.int/csr/disease/avian_influenza/en

ឱវាទអំពីការធ្វើដំណើរ (ក្រសួងការបរទេសនិងពាណិជ្ជកម្មនៃរដ្ឋាភិបាលអូស្ត្រាលី
Travel Advice (Australian Government Department of Foreign Affairs and Trade)
http://www.smartraveller.gov.au

មជ្ឈមណ្ឌលសហរដ្ឋអាមេរិកផ្នែកការគ្រប់គ្រងនិងបង្ការជំងឺ
U.S. Centers for Disease Control and Prevention
http://www.cdc.gov/flu/avian/index.htm

## ចំពោះព័ត៌មានបន្ថែម-មន្ទីរសុខាភិបាលសាធារណៈរដ្ឋ NSW

## Further information – Public Health Units in NSW

ចំពោះព័ត៌មានបន្ថែម សូមទាក់ទងវេជ្ជបណ្ឌិតលោកអ្នក មន្ទីរសុខាភិបាលសាធារណៈ ឬក៏មណ្ឌលសុខភាពសហគមន៍-សូមមើលផ្នែករដ្ឋាភិបាលរដ្ឋ NSW នៅលើទំព័រមុខនៃសៀវភៅទូរស័ព្ទពណ៌ស

For more information please contact your doctor, local public health unit or community health centre – look under NSW Government at the front of the White Pages.

| តំបន់ក្រុង<br>Metropolitan Areas | | | តំបន់ជនបទ<br>Rural Areas | | |
|---|---|---|---|---|---|
| Northern Sydney / Central Coast | Hornsby | 02 9477 9400 | Greater Southern | Goulburn | 02 4824 1837 |
| | Gosford | 02 4349 4845 | | Albury | 02 6021 4799 |
| South Eastern Sydney / Illawarra | Randwick | 02 9382 8333 | Greater Western | Broken Hill | 08 8080 1499 |
| | Wollongong | 02 4221 6700 | | Dubbo | 02 6841 5569 |
| Sydney South West | Camperdown | 02 9515 9420 | | Bathurst | 02 6339 5601 |
| | Liverpool | 02 9828 5944 | | | |
| Sydney West | Penrith | 02 4734 2022 | Hunter / New England | Newcastle | 02 4924 6477 |
| | Parramatta | 02 9840 3603 | | Tamworth | 02 6767 8630 |
| Justice Health Service | Matraville | 02 9289 2977 | North Coast | Port Macquarie | 02 6588 2750 |
| | | | | Lismore | 02 6620 7500 |
| NSW Department of Health | Nth Sydney | 02 9391 9000 | | | |
| NSW Health website | www.health.nsw.gov.au | | | | |

© NSW Department of Health 2005

បើសិនជាលោកអ្នកត្រូវការជំនួយដើម្បីប្រើទូរស័ព្ទជាភាសាអង់គ្លេស សូមទូរស័ព្ទទៅសេវាបកប្រែភាសា (TIS) លេខ 131 450 ។

លេខទូរស័ព្ទទាំងនេះគឺជាលេខត្រឹមត្រូវនៅគ្រាដែលបោះពុម្ពផ្សាយ ប៉ុន្តែមិនបានទទួលការកែតម្រូវជាហូរហែទេ។ លោកអ្នកប្រហែលជាត្រូវតែឆែករកលេខទូរស័ព្ទទាំងនេះ នៅតាមសៀវភៅទូរស័ព្ទហើយ។

លោកអ្នកអាចស្វែងរកព័ត៌មានសុខភាពថែមទៀតជាភាសាលោកអ្នក នៅតាមវិបសាយរបស់អង្គការ Multicultural Communication (ទំនាក់ទំនងពហុវប្បធម៌) នៅឯ http://mhcs.health.nsw.gov.au ។